ក្រសួងសុខាភិបាល

# គោលការណ៍ណែនាំ

# ស្តីពីការគ្រប់គ្រងគ្លីនិក
# នៃអ្នកជំងឺដែលប៉ះពាល់ជាមួយសារធាតុគីមី

# អារម្ភកថា

ការគំរាមកំហែងដោយសារធាតុគីមី ឬអាវុធគីមី គឺជាបញ្ហាសុខភាពសាធារណៈដ៏ធ្ងន់ធ្ងរ ហើយប៉ះពាល់ដល់សុខភាពបរិស្ថាន និងជាអំពើអមនុស្សធម៌ ដែលត្រូវធ្វើអន្តរាគមន៍ទប់ស្កាត់តាមគ្រប់រូបភាពជាលក្ខណៈជាតិ និងអន្តរជាតិ។ ការគ្រប់គ្រងអ្នកជំងឺដែលប៉ះពាល់ជាមួយសារធាតុគីមីពុល ឬអាវុធគីមី ឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាព គឺត្រូវសង្គ្រោះជីវិត កាត់បន្ថយផលប៉ះពាល់ដល់សុខភាព ធានាសុវត្ថិភាពអ្នកជំងឺ និងអ្នកផ្តល់សេវា ថែទាំសុខភាពឱ្យបានត្រឹមត្រូវតាមបច្ចេកទេស ដោយអនុវត្តតាមគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងគ្លីនិក នៃអ្នកជំងឺដែលបានប៉ះពាល់ជាមួយសារធាតុគីមី ដែលបានរៀបចំឡើងដោយក្រុមការងារបច្ចេកទេស និងវេជ្ជបណ្ឌិតឯកទេស នៃក្រសួងសុខាភិបាល ព្រមទាំងជំនាញការរបស់អង្គការសុខភាពពិភពលោក។

ដើម្បីអនុវត្តតាមគោលការណ៍ណែនាំ មន្ត្រីសុខាភិបាល និងបុគ្គលិកពាក់ព័ន្ធទាំងអស់ ត្រូវស្វែងយល់ និងទទួលការបណ្តុះបណ្តាលឱ្យបានត្រឹមត្រូវទៅតាមតួនាទី និងភារកិច្ចរបស់ខ្លួន ក្នុងការជួយសង្គ្រោះអ្នកជំងឺបានប៉ះពាល់ជាមួយសារធាតុគីមី ឬអាវុធគីមី រួមជាមួយវិធានការការពារខ្លួន ទប់ស្កាត់ការសាយភាយសារធាតុគីមីដែលបានប៉ះពាល់ជាមួយអ្នកជំងឺ កុំឱ្យបន្តសាយភាយចូលទៅក្នុងខ្លួនអ្នកជំងឺកាន់តែច្រើនថែមទៀត ដោយប្រើប្រាស់បច្ចេកទេស លាងសម្អាត-ជូត-លាងសម្អាត (Rinse-Wipe-Rinse Technique) ដែលមានលក្ខណៈសាមញ្ញ ប្រសិទ្ធភាព មិនត្រូវការសម្ភារៈច្រើន ហើយងាយក្នុងការអនុវត្ត។

ក្រសួងសុខាភិបាល អនុញ្ញាតឱ្យប្រើប្រាស់ **«គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងគ្លីនិក នៃអ្នកជំងឺដែលប៉ះពាល់ជាមួយសាធាតុគីមី»** សំដៅឱ្យមន្ត្រីសុខាភិបាល និងបុគ្គលិកពាក់ព័ន្ធទាំងអស់ អនុវត្តតាមស្តង់ដាណែនាំត្រឹមត្រូវមួយ ដើម្បីសង្គ្រោះជីវិតអ្នកជំងឺនៅគ្រប់មូលដ្ឋានសុខាភិបាលក្នុងកាលៈទេសៈដែលមានការវាយប្រហារដោយសារធាតុគីមី ឬអាវុធគីមី។

ក្នុងនាមក្រសួងសុខាភិបាល ខ្ញុំសូមឱ្យមន្ត្រីសុខាភិបាល និងបុគ្គលិកពាក់ព័ន្ធទាំងអស់ បន្តសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ចែករំលែកព័ត៌មាន និងធ្វើអន្តរាគមន៍ឆ្លើយតបឱ្យបានទាន់ពេលវេលា រួមទាំងការទប់ស្កាត់ការវាយប្រហារដោយ សារធាតុគីមី ឬអាវុធគីមី តាមគ្រប់មធ្យោបាយ ជាពិសេសការជួយសង្គ្រោះបឋមនៅនឹងកន្លែង ក្នុងពេលបញ្ជូនអ្នកជំងឺ និងជួយសង្គ្រោះជីវិតជនរងគ្រោះ អ្នកជំងឺ ក្នុងមូលដ្ឋានសុខាភិបាលគ្រប់កម្រិតឱ្យបានសមស្របតាមបច្ចេកទេស។

ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះ ក្រុមការងារបច្ចេកទេស និងវេជ្ជបណ្ឌិតឯកទេស នៃក្រសួងសុខាភិបាល ព្រមទាំងជំនាញការរបស់អង្គការសុខភាពពិភពលោក ដែលបានរៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងគ្លីនិក នៃអ្នកជំងឺដែលប៉ះពាល់ជាមួយសារធាតុគីមីបានទាន់ពេលវេលា។

ថ្ងៃ...ចន្ទ ២ រោច...ខែ...ស្រាពណ៍...ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី...១១...ខែ...សីហា...ឆ្នាំ២០២៥ ៨៤៧

សាស្ត្រាចារ្យ **ឈាន រ៉ា**

# មាតិកា


**មាតិកា** ........ I

**១. សេចក្តីផ្តើម** ........ ១

**២. គោលបំណង** ........ ២

**៣. លំហូរ នៃការគ្រប់គ្រងអ្នកជំងឺ** ........ ២

**៤. ការសម្រេចចិត្តថាតើអ្នកជំងឺបានប៉ះពាល់ជាមួយសារធាតុគីមី** ........ ៣

គោលការណ៍សំខាន់ៗ ........ ៣

**៥. ការការពារខ្លួន និងបុគ្គលិកផ្សេងទៀត** ........ ៤

**៦. ការត្រៀមសម្រាប់ការលាងសម្អាតសារធាតុគីមីពុលបន្ទាន់** ........ ៥

គោលការណ៍សំខាន់ៗ ........ ៥

**៧. ការលាងសម្អាតសារធាតុពុលដោយប្រើបច្ចេកទេស «លាងសម្អាត-ជូត-លាងសម្អាត»** ........ ៦

**៨. សញ្ញា និងរោគសញ្ញា នៃការប៉ះពាល់នឹងសារធាតុគីមី** ........ ៨

៨.១ ភ្នាក់ងារគីមីប្រើក្នុងសង្គ្រាម (CHEMICAL WARFARE AGENTS) ........ ៨

៨.២ ភ្នាក់ងារធ្វើឱ្យអសមត្ថភាព (INCAPACITATING AGENTS) ........ ១០

៨.៣ ភ្នាក់ងារប្រឆាំងការបះបោរ (RIOT CONTROL AGENTS - RCA) ........ ១០

៨.៤ ជាតិពុល គីមីផ្សេងទៀត (OTHER TOXIC CHEMICALS) ........ ១០

**៩. ពិធីសារសម្រាប់ការព្យាបាលការប៉ះពាល់ដោយសារធាតុគីមី ឬអាវុធគីមី** ........ ១១

៩.១ សារធាតុគីមី៖ NERVE AGENTS (e.g. sarin, GB, VX, tabun) ........ ១២

## ១. សេចក្តីផ្តើម

ក្នុងប្រវត្តិសង្គ្រាម មានសារជាតុគីមីជាច្រើនប្រភេទដែលបានប្រើប្រាស់ ក្នុងនោះឧស្ម័នពុលត្រូវបានប្រើញឹកញាប់ជាងគេ។ ឧស្ម័នពុលប្រើក្នុងសង្គ្រាមបែងចែកជា ៤ ក្រុម ទៅតាមឥទ្ធិពលសរីរវិទ្យារបស់វាទៅលើមនុស្ស។

| ល.រ | ក្រុមឧស្ម័នពុល | ឧទាហរណ៍ | ការប្រើប្រាស់ |
|---|---|---|---|
| ១ | Nerve agents | Sarin, Vx, Tabun, Novichok | – សង្គ្រាមលោកលើកទី១<br>– សង្គ្រាមនៅប្រទេសស៊ីរី |
| ២ | Blister agents | Sulfur mustard, Nitrogen, Lewisite, Phosgene oxime | – សង្គ្រាមលោកលោកលើកទី១ លើកទី២<br>– សង្គ្រាមអ៊ីរ៉ាក់ - អ៊ីរ៉ង់ |
| ៣ | Pulmonary agents | Chlorine, Phosgene, Diphosgene, Chlorpicrin | – សង្គ្រាមលោកលើកទី១ |
| ៤ | Blood agents | Hydrogen Cyanide, Arsine, Cyanogen chloride | – សង្គ្រាមលោកលើកទី២ |

ក្រុម Nerve agents ដែលប្រើប្រាស់ច្រើនជាងគេ គឺក្រុមដែលពុលដល់ប្រព័ន្ធប្រសាទ ។ ក្រុមនេះមានសារជាតុគីមីដូចជា SARIN, VX, TABUN, SOMAN, NOVICHOK ដែលមានសារជាតុគីមីផ្សំដូចថ្នាំសម្លាប់សត្វល្អិត (Organophosphate - OP)។ យន្តការដែលនាំឱ្យពុល គឺដូចគ្នាជាមួយថ្នាំសម្លាប់សត្វល្អិត ក៏ប៉ុន្តែ ការកែប្រែសារជាតុគីមីផ្សំ និងជាតុផ្សំខ្លះរបស់វាធ្វើឱ្យមានសភាពពុលមានសកម្មភាពខ្លាំងជាង។ ជាទូទៅ សារជាតុគីមីផ្សំ Organophosphate បណ្តាលឱ្យពុលប្រព័ន្ធប្រសាទស្វយ័ត (Autonomic Nervous System) ដោយវាធ្វើឱ្យមានសកម្មភាពហក់ឡើងរបស់ រ៉េសិបទ័រ (Receptors) ទាំង ២ គឺ Muscarinic និង Nicotinic របស់ប្រព័ន្ធ Cholinergic ។

ឧស្ម័នពុលក្រុមនេះ អាចជ្រាបចូលទៅក្នុងឈាមបានតាមគ្រប់ផ្លូវទាំងអស់ តាមការដកដង្ហើមចូល លេប ប៉ះស្បែក ប៉ះភ្នែកជាដើម។ រយៈពេលស្ថិតនៅមានសកម្មភាពក្នុងបរិយាកាល (Persistance) ក្រោយពេលបាចសាច ឬសាយភាយ មានការប្រែប្រួលទៅតាមសារជាតុនីមួយៗ៖

- SARIN ជាឧស្ម័នហើរ វាមិននៅសល់យូរទេ។ ជាទូទៅ ឧស្ម័ននេះនៅមានសកម្មភាពក្រោយបាច ២-៣នាទី ទៅ ២-៣ ម៉ោង។ ជាតុអាកាសក្តៅ ខ្យល់ខ្លាំងធ្វើឱ្យឧស្ម័ននេះឆាប់ហើរអស់។
- VX ជាឧស្ម័នដែលហើរតិចតួច។ ឧស្ម័ននេះ មានសកម្មភាពក្នុងបរិយាកាសក្រោយបាចច្រើនថ្ងៃ ឬច្រើនសប្តាហ៍ (ជាតុអាកាសក្តៅ-ច្រើនថ្ងៃ ជាតុអាកាសត្រជាក់-ច្រើនសប្តាហ៍) ហើយវាជាប់នៅ ដី រុក្ខជាតិ បន្លែ ខោអាវជាដើម។ ទឹកភ្លៀងអាចធ្វើឱ្យវាទៅជាល្បាយរាវ តែវានៅមានសកម្មភាពដូចធម្មតា អាចពុលដល់ប្រភពទឹក និងដី។
- TABUN (GA) វាហើរឆាប់ជាង VX ។ ក្រោយបាច TABUN នៅមានសកម្មភាពក្នុងបរិយាកាស ច្រើនម៉ោងទៅច្រើនថ្ងៃ។ TABUN ឆាប់ហើរចេញពីដី។ ទឹកភ្លៀងអាចជួយឆាប់បន្សាប TABUN បាន។
- NOVICHOK ស្ថិតនៅយូរក្នុងបរិយាកាស អាចដល់ច្រើនសប្តាហ៍ ឬខែ។ សារជាតុនេះ អាចនៅជាប់លើដី សម្លៀកបំពាក់ ឬជញ្ជាំងអាគារ។ វាឈ្នះទឹកភ្លៀង។

## ២. គោលបំណង

គោលការណ៍ណែនាំនេះ គឺសម្រាប់មន្ត្រីសុខាភិបាល និងបុគ្គលិកពាក់ព័ន្ធទាំងអស់ ជាពិសេសក្នុងផ្នែកព្យាបាល ថែទាំ ដែលមានភារកិច្ចទទួលអ្នកជំងឺរងផលប៉ះពាល់ដោយសារធាតុគីមី ឬអាវុធគីមី ដើម្បីយកទៅអនុវត្តក្នុងការជួយសង្គ្រោះ និងព្យាបាល ថែទាំ អ្នកជំងឺ ឬជនរងគ្រោះបានសមស្របតាមបច្ចេកទេស។

គំនូសបំព្រួញដែលបានបង្ហាញក្នុងគោលការណ៍ណែនាំនេះ បានតម្រង់ទិសក្នុងការកំណត់អត្តសញ្ញាណអ្នកជំងឺដែលប៉ះពាល់ជាមួយសារធាតុ ឬអាវុធគីមី។ អនុសាសន៍នានាអំពីការការពារខ្លួន នីតិវិធីសម្រាប់ការលាងសម្អាតជាតិពុល ការណែនាំសម្រាប់ការបែងចែកអ្នកជំងឺ (Triage) និងការកំណត់ប្រភេទនៃការប៉ះពាល់ ព្រមទាំងធ្វើការព្យាបាលដោយ Antidote ដល់អ្នកជំងឺដែលប៉ះពាល់ដោយសារធាតុគីមី។ មន្ត្រីសុខាភិបាល និងបុគ្គលិកពាក់ព័ន្ធ គួរសិក្សានិងទទួលបានការបណ្តុះបណ្តាលក្នុងការអនុវត្តគោលការណ៍ណែនាំនេះឱ្យបានស្របតាមស្ថានភាពរបស់មូលដ្ឋានសុខាភិបាលនីមួយៗ។

## ៣. លំហូរ នៃការគ្រប់គ្រងអ្នកជំងឺ

(INITIAL MANAGEMENT OF PATIENTS FLOWCHART)



## ៤. ការសម្រេចចិត្តថាតើអ្នកជំងឺបានប៉ះពាល់ជាមួយសារធាតុគីមី

### គោលការណ៍សំខាន់ៗ

- អ្នកជំងឺប៉ះពាល់ជាមួយសារធាតុគីមី តាមរយៈការស្រូបចូល ការប៉ះពាល់លើស្បែក ឬភ្នែក ការលេបចូល ឬការប៉ះពាល់វត្ថុបំពុល ដូចជា បំណែកអាវុធ ឬសារធាតុផ្ទុះជាដើម។
- ការប៉ះពាល់ឧស្ម័ន ចំហាយ ឬបំណែកតូចៗជាដំណក់ទឹកតូចៗ (Aerosols) ដែលអាចនឹងមិនបន្សល់ទុកនូវសញ្ញាដែលអាចមើលឃើញពីការសាយភាយបានទេ។
- អ្នកជំងឺដែលបានបញ្ជូនមកមូលដ្ឋានសុខាភិបាល បន្ទាប់ពីបានប៉ះពាល់ជាមួយសារធាតុគីមី ត្រូវបានចាត់ទុកថាមានការប៉ះពាល់ ហើយតម្រូវឱ្យមានការលាងសម្អាតជាតិពុលចេញជាបន្ទាន់។
- ការព្យាបាល ការលាងសម្អាតជាតិពុលលើអ្នកជំងឺ គួរតែធ្វើឡើងរួមជាមួយនឹងការបែងចែកជំងឺ (triage) និងការផ្តល់អន្តរាគមន៍សង្គ្រោះបន្ទាន់។
- របួសដោយសារការប៉ះទង្គិច និងផលវិបាកផ្នែកវេជ្ជសាស្រ្តផ្សេងទៀតក៏អាចកើតមានផងដែរ។

### មុនពេលអ្នកជំងឺចូលមូលដ្ឋានសុខាភិបាល គួរសួរសំណួរខាងក្រោមនេះ៖

**១. តើអ្នកជំងឺមានប្រវត្តិនៃការប៉ះពាល់យ៉ាងដូចម្តេច?**

ក. តើអ្នកជំងឺនៅទីណា? ពេលណាដែលពួកគាត់ចាប់ផ្តើមមានរោគសញ្ញា? អ្វីដែលពួកគាត់មានដំបូង? តើអ្នកដទៃមានលេចចេញរោគសញ្ញាស្រដៀងគ្នានេះដែរទេ?

ខ. តើអ្នកជំងឺបានសម្គាល់ថាមានក្លិនមិនធម្មតាដែរឬទេ? ឧទាហរណ៍ ខ្ទឹមស (បង្ហាញពី ឧស្ម័ន Mustard) ក្លិនដូចផ្លែអាល់ម៉ុនល្វីង (បង្ហាញពី Cyanide) ក្លិនដូចស្មៅ ឬចំបើងស្រស់ (បង្ហាញពី Phosgene)។

គ. យករបាយការណ៍ពីក្រុមគ្រួសារ អ្នកជំងឺ ឬសាក្សី ឬអ្នកឆ្លើយតបដំបូង។

ឃ.ត្រូវប្រើប្រាស់ព័ត៌មានឱ្យបានត្រឹមត្រូវ និងវិភាគទៅតាមបរិបទ (ឧទាហរណ៍ អាជ្ញាធរសុខាភិបាល ការអនុវត្តច្បាប់ ប្រភពប្រព័ន្ធផ្សព្វផ្សាយគួរជឿជាក់បាន)។

**២. តើអ្នកអាចសង្កេតឃើញមានសញ្ញាណាមួយនៃសារធាតុគីមីនៅលើ ឬជុំវិញអ្នកជំងឺដែរឬទេ?**

ក. ធូលី ម្សៅ ឬដំណក់សារធាតុរាវលើផ្ទៃរាងកាយ ឬសម្លៀកបំពាក់។

ខ. ការប្រែពណ៌សម្លៀកបំពាក់ ការរលាក ឬខូចសម្លៀកបំពាក់ (ឧទាហរណ៍ បង្ហាញពីប្រតិកម្មគីមី)។

គ. អ្នកដែលមិនប៉ះពាល់ដែលអមដំណើរជាមួយអ្នកជំងឺបង្ហាញរោគសញ្ញា និងសញ្ញាដែលបង្ហាញពីការប៉ះពាល់បន្ទាប់បន្សំ។

ឃ. ប្រសិនបើមាន នីតិវិធី/ឧបករណ៍ចាប់សារធាតុគីមី (ឧទាហរណ៍ ឧបករណ៍តាមដានសារធាតុគីមី ការធ្វើតេស្តរហ័សសម្រាប់ Sulfur Mustard ឬ Cholinesterase Activity) គួរត្រូវបានប្រើប្រាស់។

**៣. តើមានសញ្ញា និងរោគសញ្ញានៃការប៉ះពាល់ដែរឬទេ?**

តើអ្នកជំងឺហាក់ដូចជាមិនស្រួលខ្លួនទេ? សូមមើលបញ្ជីសញ្ញា និងរោគសញ្ញា។

ប្រសិនបើមានការសង្ស័យថាអ្នកជំងឺមានការបំពុលដោយសារធាតុគីមី ការលាងសម្អាត គឺជាអាទិភាពបន្ទាន់។

សម្លៀកបំពាក់ប្រឡាក់ ត្រូវយកចេញឱ្យបានឆាប់រហ័ស ហើយបោះចោលឱ្យបានសមរម្យជាសំណល់គីមី។

## ៥. ការការពារខ្លួន និងបុគ្គលិកផ្សេងទៀត

ឧបករណ៍ការពារខ្លួន (Personal Protective Equipment - PPE) គឺចាំបាច់សម្រាប់អ្នកឆ្លើយតបដំបូង និងបុគ្គលិកដែលទទួលខុសត្រូវចំពោះការលាងសម្អាតសារជាតុគីមី ការបែងចែកជំងឺ និងការព្យាបាលបន្ទាន់ នៅមូលដ្ឋានថែទាំសុខភាព។

### គោលការណ៍សំខាន់ៗ

- បុគ្គលិកសុខាភិបាល និងបុគ្គលិកពាក់ព័ន្ធ ភាគច្រើនបានប៉ះពាល់ជាមួយសារជាតុគីមីពុល ដែលមាននៅលើស្បែក ឬសម្លៀកបំពាក់របស់អ្នកជំងឺ ឬប៉ះភ្នាសរំអិល (Mucosal)។
- ការប្រើប្រាស់ PPE ប្រកបដោយប្រសិទ្ធភាព គឺអាស្រ័យលើការមាន PPE ប្រើប្រាស់គ្រប់គ្រាន់ និង យល់ដឹងពីរបៀបប្រើ និងរបៀបឆ្លងបន្តពីអ្នកជំងឺដែលបានប៉ះពាល់ជាមួយសារជាតុគីមីលើកដំបូង។
- ស្តង់ដាសមស្រប នៃ PPE គឺអាស្រ័យលើធនធាននៅមូលដ្ឋានសុខាភិបាល និងសារជាតុគីមីផ្សេង។
- PPE អាចធ្វើឱ្យមានការលំបាកក្នុងការធ្វើចលនា ឬចល័ត គំហើញ និងពិបាកក្នុងការប្រាស្រ័យទាក់ទងដោយសេរី (ឧទាហរណ៍៖ PPE មិនអាចប្រើក្នុងរយៈពេលយូរបានឡើយ)។
- PPE មិនអាចការពារ បានទាំងស្រុងនូវហានិភ័យនៃការជ្រៀតចូលរបស់សារជាតុគីមី ក្នុងករណីមានការរហែករបាំងការពារដោយថាហេតុ។
- PPE គួរតែត្រូវបានដោះចេញដោយប្រុងប្រយ័ត្នដើម្បីជៀសវាងការប៉ះកន្លែងប្រឡាក់។ PPE ត្រូវតែបានដោះចេញក្នុងទីតាំងដែលបានកំណត់ ហើយបោះចោលជាកាកសំណល់គ្រោះថ្នាក់។

គោលការណ៍ទូទៅនេះ ត្រូវបានប្រើប្រាស់ដើម្បីការពារបុគ្គលិកមុនពេលថែទាំ ព្យាបាលអ្នកជំងឺ ដែលប៉ះពាល់ជាមួយសារជាតុគីមីពុល។

| គ្រោះថ្នាក់ប៉ះពាល់សារជាតុរឹង ឬរាវ | គ្រោះថ្នាក់ប៉ះពាល់ដោយចំហាយទឹក ឬឧស្ម័ន |
|---|---|
| គ្រោះថ្នាក់ប៉ះពាល់ផ្ទាល់ អាចការពារបានដោយពាក់ស្រោមដៃដែលសមស្រប (កៅស៊ូ Nitrile ឬ Butyl មិនមែនជ័រ)។ ចំនួន និងកម្រាស់ស្រោមដៃដែលប្រើ គឺអាស្រ័យលើជំនាញដែលអ្នកប្រើប្រាស់ត្រូវការ។<br><br>សម្លៀកបំពាក់ដែលធន់នឹងសារជាតុគីមីក៏គួរពាក់ផងដែរ ប្រសិនបើមាន។ ប្រសិនបើមិនមានទេ ពេលនោះសម្លៀកបំពាក់ ឬអាវ (gowns) ដែលធន់នឹងទឹកដែលប្រើហើយចោល គួរតែត្រូវប្រើប្រាស់ និងផ្លាស់ប្តូរឱ្យបានទៀងទាត់។ | ម៉ាស់វះកាត់ និងម៉ាសប្រើក្នុងផ្នែកវេជ្ជសាស្ត្រ មិនអាចការពារផ្លូវដង្ហើម ឬភ្នាសពីការសាយភាយសារជាតុគីមីពុលបានឡើយ។<br><br>ឧបករណ៍សម្រាប់ដកដង្ហើម និងបន្សុទ្ធខ្យល់ (Air-purifying respirator) ជាមួយនឹងតម្រងធ្យូង (Activated charcoal filter) ឬឧបករណ៍ដកដង្ហើមដោយខ្លួនឯង (Self-contained breathing apparatus) អាចជួយកាត់បន្ថយការប៉ះពាល់ជាមួយការសាយភាយសារជាតុគីមីជាឧស្ម័ន។<br><br>ឧបករណ៍ដកដង្ហើម (Respirators) ត្រូវការការបណ្តុះបណ្តាលក្នុងការប្រើប្រាស់ ការធ្វើតេស្តសុវត្ថិភាព និងត្រឹមត្រូវតាមទំហំ។ |

## ៦. ការត្រៀមសម្រាប់ការលាងសម្អាតសារធាតុគីមីពុលបន្ទាន់

ការលាងសម្អាតសារធាតុគីមីពុល គឺជាការកាត់បន្ថយ ឬកម្ចាត់សារធាតុពុលដើម្បីកុំឱ្យបង្ករគ្រោះថ្នាក់បន្តទៀត។ ការធ្វើបែបនេះសម្រេចបានតាមរយៈការកម្ចាត់ ឬសម្អាតលើរាងកាយ សម្លៀកបំពាក់ ឬដោយការធ្វើឱ្យអសកម្មសារធាតុគីមី។ ការលាងសម្អាតសារធាតុគីមីពុលបន្ទាន់ពាក់ព័ន្ធនឹងសកម្មភាពដែលអាចអនុវត្តបានឆាប់តាមដែលអាចធ្វើទៅបានបន្ទាប់ពីបានប៉ះពាល់ ដោយមានគោលបំណងកាត់បន្ថយការស្រូបយក និងកំណត់ហានិភ័យនៃការប៉ះពាល់បន្ទាប់បន្សំ។

វិធីសាស្ត្រសម្រាប់លាងសម្អាតជាតិពុលអាចត្រូវបានកែសម្រួលទៅតាមស្ថានភាព និងធនធានដែលមាន។ វិធីសាស្ត្រលាងសម្អាតជាតិពុលអ្នកជំងឺមាន ២ របៀប «សើម» (ប្រើទឹក) ឬ «ស្ងួត» (ដោះសម្លៀកបំពាក់ និងប្រើសម្ភារៈបឺតស្រូប)។ សារធាតុគីមីពុលដែលខាប់ ឬជាតិប្រេង អាចពិបាកនឹងកម្ចាត់សម្អាត ដោយវិធីសាស្ត្រតែមួយ។

### គោលការណ៍សំខាន់ៗ

- អ្នកជំងឺដែលបានប៉ះពាល់សារធាតុពុល ទោះមិនមានរោគសញ្ញាក៏ដោយ ក៏ត្រូវលាងសម្អាតសារធាតុគីមីពុលនៅខាងក្រៅ មុនពេលចូលទៅក្នុងកន្លែងថែទាំសុខភាព។
- ការដោះសម្លៀកបំពាក់ គឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពខ្ពស់ក្នុងការលាងសម្អាតសារធាតុគីមីពុល។
- ការលាងសម្អាតសារធាតុគីមីពុលគួរតែត្រូវបានអនុវត្ត ដោយបុគ្គលិកដែលបានបណ្ដុះបណ្ដាល និងពាក់សម្ភារៈការពារខ្លួន (PPE) ត្រឹមត្រូវ។
- បើអាច ការលាងសម្អាតសារធាតុគីមីពុលដោយខ្លួនឯង ត្រូវធ្វើទៅតាមនិតិវិធីដែលបានណែនាំច្បាស់លាស់។
- វិធីសាស្ត្រលាងសម្អាតសារធាតុគីមីពុល មិនថា «ស្ងួត» ឬ «សើម» គួរតែត្រូវបានសម្របតាមធនធាន និងស្ថានភាពជាក់ស្ដែង។
- ការលាងសម្អាតសារធាតុគីមីពុលត្រូវធ្វើឡើងស្របពេលជាមួយនឹងការត្រួតពិនិត្យ និងការផ្ដល់អន្តរាគមន៍សង្គ្រោះបន្ទាន់។
- កាកសំណល់ ឬសម្លៀកបំពាក់ដែលមានប្រឡាក់សារធាតុគីមីពុល ត្រូវតែបោះចោលដោយសុវត្ថិភាព។

ត្រូវប្រាកដថាតំបន់ ឬទីកន្លែងលាងសម្អាតជាតិពុលត្រូវបានកំណត់ និងហ៊ុមព័ទ្ធដោយមានចំណុចតែមួយសម្រាប់ច្រកចូល/ចេញ ហើយបុគ្គលទាំងអស់ដែលចាកចេញពីតំបន់នោះត្រូវបានលាងសម្អាតជាតិពុល រួចរាល់។ បុគ្គលិកសន្តិសុខ គួរតែត្រូវបានចាត់តាំងទៅកាន់តំបន់ ឬទីកន្លែងនោះសម្រាប់ការគ្រប់គ្រងអ្នករងគ្រោះ និងដើម្បីជានាលំហូរត្រឹមត្រូវនៃបុគ្គលចូល/ចេញពីតំបន់ទីកន្លែងលាងសម្អាតជាតិពុល។ បុគ្គលិកទាំងនេះត្រូវចេះប្រើ PPE បានត្រឹមត្រូវ។ អាស្រ័យលើធនធានដែលមាន បុគ្គលិកពេទ្យត្រូវសម្រេចចិត្តជាមុនអំពីអាទិភាពនៃការជួយសង្គ្រោះជនរងគ្រោះដែលត្រូវធ្វើមុនការលាងសម្អាតសារធាតុគីមី ឬត្រូវធ្វើក្នុងពេលសង្គ្រោះជីវិតជនរងគ្រោះ។

ឧបករណ៍ជាមូលដ្ឋានសម្រាប់លាងសម្អាតសារធាតុគីមីពុលបន្ទាន់ «លាងសម្អាត-ជូត-លាងសម្អាត» ៖

- កន្ត្រៃ
- ធុងទឹក (ទំហំ ៥-១០ លីត្រ)
- អេប៉ុង ច្រាសទន់ ក្រណាត់លាង

- ប្រភពទឹកស្អាត (ទឹកក្តៅឧណ្ឌៗ) ទុយោទឹកសម្រាប់លាងជម្រះសម្អាត ទឹកសាលីនសម្រាប់លាងរបួស ភ្នែក មាត់ និងភ្នាសផ្សេងទៀត ប្រើទឹកបន្សុទ្ធសម្រាប់ឧស្ម័ន Mustard (បើអាចធ្វើបាន)
- សាប៊ូរាវ ឬទឹក ឬសាប៊ូកក់សក់
- កន្សែង/ក្រណាត់ស្ងួត
- ថង់ប្លាស្ទិកធំ (សម្រាប់ដាក់សម្លៀកបំពាក់)
- ស្លាកសញ្ញា/ប៊ិចសរសេរ
- ធុងរឹងមាំសម្រាប់ដាក់ឧបករណ៍លាងសម្អាតជាតិពុលដែលប្រើរួច
- សម្លៀកបំពាក់ជំនួស ឬក្រណាត់ ឬភួយ
- គ្រែ

ការដោះសម្លៀកបំពាក់ដែលមានជាតិពុលចេញបានឆាប់រហ័ស គឺអាចជួយកាត់បន្ថយផលប៉ះពាល់បានយ៉ាងឆាប់រហ័សនៃការសាយភាយសារធាតុគីមីពុល។

- ពន្យល់ពីអ្វីដែលនឹងត្រូវធ្វើមុនពេលចាប់ផ្តើម និងបន្តរហូតដល់ចប់។
- ដោះ ឬកាត់សម្លៀកបំពាក់ថ្នមៗឱ្យបានលឿន។ ចៀសវាងការទាញសម្លៀកបំពាក់ចេញពីក្បាល។ ប្រសិនបើសម្លៀកបំពាក់ជាប់នឹងអ្នកជំងឺ កុំហែក ឬទាញ ដោយបន្ទើម ឱ្យបានសមស្របជាមួយទឹករហូតទាល់តែសម្លៀកបំពាក់អាចរហែកចេញពីស្បែក ឬភ្នាសបាន។
- ប្រើកន្ត្រៃ ដើម្បីកាត់សម្លៀកបំពាក់ ជៀសវាងកន្លែងរាងកាយដែលងាយរងគ្រោះ ឬមានរបួស។ យកសម្លៀកបំពាក់ចេញដោយប្រុងប្រយ័ត្ន ដើម្បីកុំឱ្យមានគ្រោះថ្នាក់។
- ដោះស្បែកជើងចេញ ព្រោះវាអាចមានសារធាតុកខ្វក់ និងដីជាប់ជាមួយ។
- ដោះគ្រឿងអលង្ការ និងគ្រឿងប្រើប្រាស់ទាំងអស់ ដូចជា នាឡិកា ចិញ្ចៀន ឧបករណ៍ជំនួយការស្តាប់ និងកញ្ចក់ភ្នែក។
- បត់សម្លៀកបំពាក់ខាងក្នុងចេញក្រៅ ដើម្បីទប់ស្កាត់ការចម្លងរោគ។ វ៉ែនតាអ្នកជំងឺត្រូវលាងសម្អាតសារធាតុគីមីពុល មុនប្រគល់ជូនអ្នកជំងឺប្រើប្រាស់វិញ។
- ដាក់សម្លៀកបំពាក់ និងគ្រឿងប្រើប្រាស់ចូលក្នុងថង់ប្លាស្ទិកធំមួយ ហើយដាក់ស្លាកថាជាវត្ថុគ្រោះថ្នាក់។
- លើកអ្នកជំងឺពីសម្លៀកបំពាក់ដែលកាត់ចេញ ទៅដាក់លើគ្រែស្អាត និងមានភួយ។
- ការលាងសម្អាតជាតិពុលនៅកន្លែងដែលរងផលប៉ះពាល់ (សូមមើលព័ត៌មានលម្អិតខាងក្រោម)។
- បញ្ហាប្រឈមជាក់ស្តែងដែលទាក់ទងនឹងការដោះសម្លៀកបំពាក់ គឺរក្សាឯកជនភាពរបស់ជនរងគ្រោះ និងការផ្តល់សម្លៀកបំពាក់ថ្មីជំនួស។

## ៧. ការលាងសម្អាតសារធាតុពុលដោយប្រើបច្ចេកទេស «លាងសម្អាត-ជូត-លាងសម្អាត»

ការលាងសម្អាតសារធាតុគីមីពុលសើមបន្ទាន់ដោយប្រើបច្ចេកទេស «លាងសម្អាត-ជូត-លាងសម្អាត (Rinse-Wipe-Rinse Technique)» គឺជាវិធីសាមញ្ញ មានប្រសិទ្ធភាព និងមិនទាមទារឧបករណ៍ និងការបណ្តុះបណ្តាលច្រើនទេ។ បច្ចេកទេសនេះអាចត្រូវបានកែសម្រួលទៅតាមស្ថានភាព និងធនធានដែលមាន។ ប្រសិនបើពុំមានសាប៊ូ ការលាងសម្អាតសារធាតុគីមីពុលអាចអនុវត្តបានដោយប្រើទឹក។

ជំហានទី ១

- ជូតសារធាតុរាវទាំងអស់លើស្បែកចេញ ដោយប្រើសម្ភារៈបឺតស្រូបយកវត្ថុរាវបានលឿន ដូចជា ស្បៃរុំរបួស ឬក្រដាសជូតមាត់ជាដើម។

ជំហានទី ២

- លាងសម្អាតទីកន្លែងប៉ះពាល់សារធាតុគីមីដោយថ្នមៗជាមួយទឹកសាប៊ូ (ទឹកសាលីន ០,៩% សម្រាប់កន្លែងរបួស) ដើម្បីជួយពន្លឺតសារធាតុគីមីពុល កម្ចាត់ភាគល្អិត និងសារធាតុគីមីដែលងាយរលាយក្នុងទឹក ដោយចាប់ផ្តើមសម្អាតមុនគេលើមុខ ផ្លូវដង្ហើម ហើយចុះទៅដល់ម្រាមជើង។ យកចិត្តទុកដាក់ជាពិសេសចំពោះផ្នត់ស្បែក ផ្នត់សាច់ដុំ ក្រចក ត្រចៀក និងសក់។ លាងភ្នែកឱ្យបានច្រើនជាមួយទឹកសាលីន ០,៩% (ឬទឹកបន្សុទ្ធសម្រាប់សារធាតុពុលប្រភេទ Sulphur mustard) តាមតម្រូវការ។ បើអាចធ្វើទៅបាន ប្រើទឹកឱ្យបានច្រើន ពីព្រោះការប្រើទឹកតិចក្នុងការលាងសម្អាតមួយអាចនាំឱ្យសារធាតុគីមីមួយចំនួនរាលដាល និងស្រូបចូលក្នុងខ្លួនបាន។

ជំហានទី ៣

- ជូតសម្អាតទីកន្លែងដែលរងផលប៉ះពាល់ថ្នមៗ ជាមួយអេប៉ុង ឬច្រាសទន់ ឬក្រណាត់លាង ដើម្បីជួយកម្ចាត់សារធាតុគីមីសរីរាង្គ និងសារធាតុគីមីឥន្ទនៈ (មិនរលាយក្នុងទឹក)។ ត្រូវប្តូរអេប៉ុង និងក្រណាត់លាងជាប្រចាំ។

ជំហានទី ៤

- លាងសម្អាតទីកន្លែងដែលរងផលប៉ះពាល់ថ្នមៗ។

ជំហានទី ៥

- សម្ងួតកន្លែងដែលបានសម្អាតថ្នមៗ ដោយកន្សែងដែលអាចចោលបាន។

ជំហានទី ៦

- ផ្ទេរអ្នកជំងឺទៅលើគ្រែថ្មីនៅកន្លែងស្អាត ហើយលាងសម្អាតគ្រែដែលមានជាប់សារធាតុគីមីពុល សម្រាប់ប្រើប្រាស់នៅពេលក្រោយ។

ជំហានទី ៧

- ត្រូវប្រាកដថាបុគ្គលិកទាំងអស់ បានសម្អាតខ្លួនមុនពេលចាកចេញពីទីកន្លែងដែលបានសម្អាតជាតិពុលដល់អ្នកជំងឺ ដោយផ្លាស់ប្តូរសម្លៀកបំពាក់ថ្មីជាដើម។

ក្នុងការថែទាំអ្នកជំងឺជាបន្តបន្ទាប់ ត្រូវទុកដាក់កាកសំណល់ដែលមានជាតិពុលឱ្យមានសុវត្ថិភាព។ ជាមួយគ្នានេះ ប្រសិនបើមិនមានសាប៊ូ ក្រណាត់ ច្រាសទន់ៗសម្រាប់សម្អាតនោះទេ អ្នកអាចលាងជាមួយទឹកធម្មតាបាន។ កាកសំណល់រឹង និងទឹកបង្ហូរចេញទាំងអស់ពីដំណើរការលាងសម្អាតជាតិពុល ត្រូវគ្រប់គ្រងឱ្យបានសមស្របតាមបច្ចេកទេស និងសុវត្ថិភាព។ ការអនុវត្តបែបនេះមានសារៈសំខាន់សម្រាប់ការទប់ស្កាត់ ការសាយភាយសារធាតុគីមីពុល។

## ៨. សញ្ញា និងរោគសញ្ញា នៃការប៉ះពាល់នឹងសារធាតុគីមី

### ៨.១ ភ្នាក់ងារគីមីប្រើក្នុងសង្គ្រាម (CHEMICAL WARFARE AGENTS)

#### ៨.១.១ សារធាតុគីមីពុលប៉ះពាល់ប្រព័ន្ធប្រសាទ (Eg. Sarin/GB, VX, Tabun)

ករណីពុលស្រួចស្រាវ (កន្លែងប៉ះផ្ទាល់ និងឧស្ម័នពុល) សកម្មភាពកើនឡើងនៃរ៉េសិបទ័រ ៖

ទី១. រ៉េសិបទ័រមូស្ការីនីក (Receptor Muscarinic) បណ្តាលឱ្យចុកពោះ រាក បែកញើស លេចនោមច្រើន ហៀរទឹកភ្នែក ហៀរសំបោរ ឡើងស្លេះ បេះដូងដើរយឺត តឿតទងសួត កូនក្រមុំភ្នែករួមតូច។

ទី២. រ៉េសិបទ័រនីកូទីនីក (Receptor Nicotinic) ធ្វើឱ្យញ័រសាច់ (Fasciculation) ខ្សោយសាច់ដុំអាចរហូតដល់ខ្សោយសាច់ដុំដង្ហើម នាំឱ្យដកដង្ហើមមិនរួច ញ័រញ៉័រ ឡេះឡះ វង្វេងវង្វាន់ ប្រកាច់ ឬសន្លប់។ ករណីខ្លះអាចស្លាប់ភ្លាមៗ ដោយសារការដកដង្ហើមមិនរួច និងប្រកាច់។ ថ្នាំសត្វល្អិតមានរោគសញ្ញាច្រើនទាក់ទងនឹងរ៉េសិបទ័រមូស្ការីនីក និងមានរោគសញ្ញាតិចតួចទាក់ទងនឹងរ៉េសិបទ័រនីកូទីនីក (Receptor Nicotinic)។ ផ្ទុយទៅវិញ ផ្សែងពុលមានរោគសញ្ញា នីកូទីនីកច្រើន និងមានរោគសញ្ញាតិចតួចទាក់ទងនឹងរ៉េសិបទ័រមូស្ការីនីក ហើយមានសកម្មភាព រហ័សជាង។

❖ **សញ្ញា និងរោគសញ្ញា**

- **កម្រិតស្រាល**
  - ការប្រឈមតិចតួច ឬនៅឆ្ងាយបន្តិចពីកន្លែងមានឧស្ម័នពុលមានរោគសញ្ញាស្រាលជាង
  - ប៉ុន្មាននាទី ឬ ២-៣ម៉ោង ក្រោយការប៉ះឧស្ម័នពុលអាចមានអាការៈដូចជា ហៀរសំបោរ ក្អកតិចតួច ថប់ៗ និងឈឺក្បាលតិចតួច។ បើពិនិត្យមើលកូនក្រមុំភ្នែកឃើញរួមតូច (Miosis)។ ឈឺភ្នែក និងមានគំហើញព្រិល នៅលើស្បែកកន្លែងដែលមិនបានគ្របដណ្តប់ មានចេញញើសច្រើន និងសាច់ដុំមានកន្ត្រាក់តិចៗដោយឯកឯង។
  - បើមិនទទួលបានការព្យាបាលទេ ៤-៥ម៉ោងក្រោយមក ជនរងគ្រោះនឹងចាប់ផ្តើមមានអារម្មណ៍ថាអស់កម្លាំងខ្លាំង និងចុះខ្សោយ។
  - មានករណីមួយចំនួនអាចមានអាការៈក្អួត ចង្អោរ ឬចុកពោះ។ ឈឺក្បាលខ្លាំងជាងមុន និងមានករណីខ្លះទៀតមានវង្វេង ឬឡេះឡះ។ ករណីខ្លះ មានអាការៈណែនទ្រូង ហត់ពិបាកដកដង្ហើម។
  - មានករណីមួយចំនួនមានអាការៈវិលមុខ តឹងទ្រូង ក្អកបែកញើស ចេញទឹកមាត់ ចេញទឹកភ្នែក ចង្អោរ បេះដូងដើរយឺត និងសម្ពាធឈាមថយចុះ។
  - **ការវិវត្តន៍៖** រោគសញ្ញាតិចតួចអាចបាត់ទៅវិញក្នុងរយៈពេល ៤-៥ថ្ងៃ ទៅ ២-៣សប្តាហ៍ ដោយសារសរីរាង្គអាចបញ្ចេញចោលជាតិពុលបន្តិចម្តងៗពីក្នុងខ្លួនដោយខ្លួនឯង។ ប៉ុន្តែរោគសញ្ញាខ្លះអាចវិវត្តជាធ្ងន់ធ្ងរប្រសិនបើមិនបានព្យាបាលទាន់ពេលវេលា។
  - **ប្រយ័ត្ន៖** រោគសញ្ញាខ្លះៗខាងលើអាចមានការភ័ន្តច្រឡំជាមួយអាការៈស្រដៀងគ្នាដូចជា៖
    - អស់កម្លាំងក្រោយពីមានសកម្មភាពខ្លាំងក្លា ប្រឹងខ្លាំង ឬមានសភាពស្ត្រេសខ្លាំង។ ភ្នែកប្រឹងសម្លឹងខ្លាំង និងមិនបានសម្រាកគ្រប់គ្រាន់។
    - ការទទួលទានអាហារ ឬទឹកមិនស្អាតនាំឱ្យក្អួត រាក និងចុះពោះជាដើម។

- **កម្រិតមធ្យមៈ** មានអាការៈទ្បេះទ្បះ ប្រកាច់ ងងុយដេក បាត់បង់ស្មារតី កូនក្រមុំភ្នែករួមតូច ឬ រីក (Miosis / mydriasis) * ឈឺភ្នែក ញាក់សាច់ដុំ, (fasciculation) ឈឺពោះ ក្អួត រាក បេះដូងដើរយឺត បេះដូងដើរលឿន*, សម្ពាធឈាមថយចុះ / សម្ពាធឈាមឡើង* ស្លេកស្លាំង ពិបាកដកដង្ហើម (bronchorrhoea, bronchospasm, respiratory depression)។
- **កម្រិតធ្ងន់ធ្ងរៈ** មានអាការៈប្រកាច់ ខ្វិន ទន់អវៈយវៈ (flaccid paralysis), សន្លប់បាត់ស្មារតី ការលេចនោម/ការបន្ទោរបង់មិនដឹងខ្លួន (Respiratory failure, pulmonary oedema, cyanosis)។

❖ **រោគវិនិច្ឆ័យ**

- ដើម្បីព្យាបាលៈ រោគវិនិច្ឆ័យត្រូវធ្វើដោយការពិនិត្យសញ្ញារួមនឹងប្រវត្តិ ឬដំណើររឿងដែលនាំ ឱ្យមានរោគសញ្ញា។ មានរោគសញ្ញាច្បាស់ (ចុកពោះ រាក បែកញើសច្រើន លេចនោម ហៀរទឹកភ្នែក ហៀរសំបោរ ឡើងស្លេះ បេះដូងដើរយឺត តឿតទងសួត កូនក្រមុំភ្នែករួមតូច ឬ ញ័រញ៉ រ ទ្បេះទ្បះ វង្វេងវង្វាន់ ខ្សោយសាច់ដុំជាដើម)។
- ដើម្បីបញ្ជាក់ថាពិតជាពុលភ្នាក់ងារប៉ះពាល់ប្រព័ន្ធប្រសាទ (Nerve gas)៖ តេស្តវាស់សកម្មភាពរបស់ Cholinesterase ក្នុងឈាម (Cholinesterase activity assays) (បើមាន)។ អាចធ្វើបានរហូតដល់ ២-៣ សប្តាហ៍ក្រោយការប្រឈមក្នុងករណីមិនបានប្រើពួក Oxime។
- ដើម្បីបញ្ជាក់ប្រភេទភ្នាក់ងារប៉ះពាល់ប្រព័ន្ធប្រសាទ (Nerve gas)៖ ត្រូវធ្វើតេស្ត Detection of Nerve Agent Metabolites បើអាចធ្វើបាន។

### ៨.១.២ សារធាតុគីមី BLISTER AGENTS (e.g. Sulfur mustard, lewisite)

អាចធ្វើអោយចេញទឹកភ្នែក រមាស់ភ្នែក រលាកភ្នែក មានបញ្ហាកូនក្រមុំភ្នែក (corneal Damage) សំឡេងស្អក ឈឺបំពង់កជាដើម។

❖ **រោគសញ្ញា និងរោគសញ្ញាកើតមានយឺតយ៉ាវ (ច្រើនម៉ោងក្រោយ)៖**

- ក្រហម និងពងបែកលើស្បែក ដោយមានការឈឺចាប់។ ក្រោយមកទៀត ការដាច់រលាត់នៃស្រទាប់ស្បែកខាងលើ។
- បង្កពងបែកដោយយឺតៗ ពេលមានការប៉ះពាល់ទៅនឹង sulfur mustard ប៉ុន្តែបង្កពងបែកយ៉ាងឆាប់រហ័សពេលប៉ះពាល់ទៅនឹង Lewisite ។
- ភាពលំបាកក្នុងការដកដង្ហើម ជាធម្មតាអាចកើតមាននៅពេលបន្ទាប់។
- ប្រព័ន្ធភាពស៊ាំចុះខ្សោយ។

### ៨.១.៣ សារធាតុគីមី CYANIDE

❖ **រោគសញ្ញា និងរោគសញ្ញា**

- ដង្ហក់រកខ្យល់ ការថប់ដង្ហើម
- កូនក្រមុំភ្នែករីក (Mydriasis)
- បេះដូងដើរញាប់ វិបត្តិចង្វាក់បេះដូង (Arythmias)
- ប្រកាច់
- ចង្អោរ
- ស្បែកពណ៌ស្វាយស្លេក (cyanosis អាចកើតមាន)

## ៨.២ ភ្នាក់ងារធ្វើឱ្យអសមត្ថភាព (INCAPACITATING AGENTS)

### ៨.២.១ សារធាតុគីមីៈ INCAPACITANTS BZ, Agent 15

- សញ្ញា និងរោគសញ្ញា
  - រីកកូនក្រមុំភ្នែក (Mydriasis)
  - ខ្សោយស្មារតី វង្វេង ភាពភ័យរន្ធត់
  - ស្ងួតមាត់ និងស្បែក
  - បេះដូងដើរញាប់ (Tachycardia)
  - សីតុណ្ហភាពក្នុងខ្លួនឡើងក្តៅ (Hyperthermia)
  - បាត់បង់ចលនាសាច់ដុំ (Ataxia)

### ៨.២.២ សារធាតុគីមីៈ INCAPACITANTS Opioids

- រោគសញ្ញា និងរោគសញ្ញា
  - រួមកូនក្រមុំភ្នែកភ្នែក (Miosis)
  - ងងុយដេក
  - វិលមុខ
  - បាត់បង់ចលនាសាច់ដុំ (ataxia)
  - សន្លប់
  - វិបត្តិផ្លូវដង្ហើម
  - ជំងឺធ្លាក់ទឹកចិត្ត
  - ស្ទះដង្ហើម

## ៨.៣ ភ្នាក់ងារប្រឆាំងការបះបោរ (RIOT CONTROL AGENTS - RCA)

ឧស្ម័នបង្ហូរទឹកភ្នែក / ភ្នាក់ងារគ្រប់គ្រងកុបកម្ម (Tear gas / riot control agents)

- រោគសញ្ញា និងរោគសញ្ញា
  - មានអារម្មណ៍ ក្រហាយដល់ភ្នែក និងមានស្លេស
  - ហៀរទឹកភ្នែក ហៀរទឹកមាត់
  - ហៀរសំបោរ
  - តឹងទ្រូង
  - ឈឺក្បាល
  - ចង្អោរ

## ៨.៤ ជាតិពុល គីមីផ្សេងទៀត (OTHER TOXIC CHEMICALS)

### ៨.៤.១ សារធាតុគីមីៈ ក្លរីន (Chlorine)

- សញ្ញា និងរោគសញ្ញា
  - ភ្នែកឡើងក្រហម និងហៀរទឹកភ្នែក
  - រលាកផ្លូវដង្ហើមផ្នែកខាងលើ

- ក្អក (អាចមានស្លេស)
- ដកដង្ហើមមិនរួច ឬ ស្ទះឆ្អក់ តឹងទ្រូង
- សំឡេងស្អក
- ចង្អោរ និងក្អួត
- សញ្ញា និងរោគសញ្ញាយឺតយ៉ាវ (ពីរបីម៉ោង)៖ ហើមសួត

៨.៤.២ សារធាតុគីមី៖ Phosgene

- **សញ្ញា និងរោគសញ្ញា**
  - ភ្នែកឡើងក្រហម និងហៀរទឹកភ្នែក
  - ចង្អោរ និងក្អួត
  - តឹងទ្រូង ដកដង្ហើមខ្លីៗ
  - សម្ពាធឈាមថយចុះ
  - ហើមសួត

## ៩. ពិធីសារសម្រាប់ការព្យាបាលការប៉ះពាល់ដោយសារធាតុគីមី ឬអាវុធគីមី

ការសង្ខេបអំពីពិធីសារសម្រាប់ការព្យាបាល តែមិនគ្របដណ្ដប់លើគ្រប់ករណីទាំងអស់នោះទេ។

- បញ្ជីឈ្មោះថ្នាំបន្សាប (antidote regimens) ដែលបានរៀបរាប់ខាងក្រោម គឺសម្រាប់ជាការណែនាំតែប៉ុណ្ណោះ ពីព្រោះមានថ្នាំបន្សាបជាច្រើនទៀតដែលកំពុងត្រូវបានប្រើប្រាស់ក្នុងផ្នែកវេជ្ជសាស្ត្រនៅក្នុងបណ្ដាប្រទេសផ្សេងៗគ្នា។
- អ្នកជំងឺទាំងអស់ដែលបានប៉ះពាល់ ត្រូវតែធ្វើការវាយតម្លៃផ្នែកវេជ្ជសាស្ត្រតាមបែប "ABCDE" ។
- ការថែទាំ គាំទ្រ រួមទាំងវិធីជំនួយដង្ហើម (invasive ventilation) (ប្រសិនបើមាន) គឺមាន សារៈសំខាន់ណាស់ក្នុងការគ្រប់គ្រងអ្នកជំងឺដែលបានប៉ះពាល់ ដោយភ្ជាប់ជាមួយនឹងការប្រើប្រាស់ថ្នាំបន្សាប (antidote regimens)។
- អ្នកជំងឺអាចធ្លាក់ខ្លួនឈឺកាន់តែធ្ងន់ធ្ងរ ប្រសិនបើការលាងសម្អាតជាតិពុល (decontamination) មិនបានសម្រេចពេញលេញ ដូច្នេះអ្នកជំងឺទាំងអស់គួរតែត្រូវបានតាមដានឱ្យបានជាប់លាប់។
- ត្រូវប្រុងប្រយ័ត្នចំពោះលទ្ធភាពនៃការរងរបួសដោយសារការផ្ទុះ និងរបួសការជ្រៀតចូលជ្រៅដោយបំណែកនៃគ្រាប់បែក (penetrating injury)។
- បន្ទាប់ពីការឆ្លើយតបដំបូង គួរតែស្វែងរកការប្រឹក្សាពីអ្នកជំនាញ ដើម្បីដោះស្រាយផលវិបាកដែលអាចកើតមាន។

(១) ABCDE: A-Airway (ផ្លូវដង្ហើម); B-Breathing (ការដកដង្ហើម); C-Circulation (ចរន្តឈាម); D-Disability (ពិការភាព); E-Exposure and Environment (ការប៉ះពាល់ និងបរិស្ថាន)។

នៅមន្ទីរព្យាបាល គ្រប់ករណីសង្ស័យថាពុលជាតិគីមី ត្រូវ៖

- ផ្លាស់ប្តូរសម្លៀកបំពាក់ចេញភ្លាមៗជៀសវាងជាតិគីមីដែលប្រឡាក់ជាប់ខោអាវដែលអាចចូលតាមស្បែកបន្ថែមទៀតបាន។
- ងូតទឹក ឬជូតសម្អាតខ្លួន។

៩.១ សារធាតុគីមី៖ NERVE AGENTS ( e.g. sarin, GB, VX, tabun )

៩.១.១ ថ្នាំបន្សាប ( Antidote )៖ ATROPINE

| ការព្យាបាលដំបូង | កំណត់ចំណាំ និងការព្យាបាលគាំទ្រ |
|---|---|
| **មនុស្សពេញវ័យ៖**<br>– 2mg ចាក់ IM ឬ IV រៀងរាល់ ៥-១០ នាទីម្តង។ សម្រាប់ករណីមានរោគសញ្ញាធ្ងន់ធ្ងរ អាចផ្តល់រហូតដល់ 6mg សម្រាប់ការចាក់ដំបូង។<br><br>**កុមារ៖**<br>– 0.05-0.1 mg/kg ចាក់ IM ឬ 0.02 mg/kg ចាក់ IV ( មិនលើសពី 2mg ក្នុងមួយដូស ) រៀងរាល់ ៥-១០ នាទីម្តង។ ដូសខ្ពស់ជាងនេះនៃ Atropine អាចនឹងត្រូវបានផ្តល់ប៉ុន្តែត្រូវតែលៃតម្រូវទៅតាមការឆ្លើយតបគ្លីនិក។ | • ត្រូវផ្តល់ជូនគ្រប់ករណីមធ្យម និងធ្ងន់ធ្ងរទាំងអស់។<br>• កែតម្រូវ Hypoxia ប្រសិនបើអាចធ្វើទៅបាន មុនពេលផ្តល់ Atropine ដើម្បីការពារ Arrhythmia ដែលគំរាមកំហែងដល់អាយុជីវិត។<br>• ការជួយដកដង្ហើម ( Assisted ventilation ) អាចនឹងត្រូវបានប្រើប្រាស់សម្រាប់អ្នកជំងឺដែលប៉ះពាល់ធ្ងន់ធ្ងរ។<br>• ការតាមដានដោយប្រុងប្រយ័ត្នត្រូវតែធ្វើក្នុងការប្រើប្រាស់ Atropine ដើម្បីធានាថាដូសគ្រប់គ្រាន់ត្រូវបានផ្តល់ជូន និងដើម្បីការពារការប្រើប្រាស់លើសកម្រិត។<br>• ប្រសិនបើអាចធ្វើបាន ត្រូវភ្ជាប់អ្នកជំងឺនឹងម៉ាស៊ីនត្រួតពិនិត្យចង្វាក់បេះដូង ( ECG monitor )។<br>• កុំប្រើ Pupil size ជាការកំណត់សម្រាប់វាយតម្លៃការផ្តល់ atropine។<br>• អាចត្រូវប្រើ Atropine ជាច្រើនដងរហូតដល់បាន "Atropinisation" ដែលសម្គាល់ដោយ៖<br>  ○ ស្តាប់សួតទៅមិនលឺសម្លេងស្លេស ( គ្រុលៗ ) ( Clear chest on auscultation )។<br>  ○ ចង្វាក់បេះដូងលើសពី 80 ចង្វាក់ក្នុងមួយនាទី។<br>  ○ សម្ពាធស៊ីស្តូល លើសពី 80 mmHg<br>  ○ ស្បែកស្ងួត ( Axillae )។ |

| | |
|---|---|
| | • ការចាប់ផ្តើមនៃរោគសញ្ញាពីការប៉ះពាល់ស្បែកជាមួយនឹងសារធាតុគីមីក្នុងទម្រង់រាវអាចនឹងមានការពន្យារពេល។ ត្រូវតាមដានអ្នកជំងឺដែលបានប៉ះពាល់ដែលគ្មានរោគសញ្ញា។<br>• ទម្រង់ Autoinjector គឺមានសម្រាប់ថ្នាំបន្សាបប្រភេទនេះ។ ស្តង់ដា Autoinjector គឺប្រើប្រាស់សម្រាប់តែមនុស្សពេញវ័យប៉ុណ្ណោះ ដោយសភាពម្ជុលវែងពេកមិនសមស្របសម្រាប់សាច់ដុំរបស់កុមារតូច ហើយកម្រិតថ្នាំបន្សាបក៏ខ្ពស់ពេកដែរ។ ការប្រើប្រាស់ Autoinjector ស្តង់ដា អាចត្រូវពិចារណាក្នុងករណីកុមារពុលធ្ងន់ធ្ងរដែលត្រូវការការព្យាបាលបន្ទាន់ ទោះជាយ៉ាងណាក៏ដោយ គួរពិចារណាឱ្យបានច្បាស់លាស់ ដោយពិនិត្យមើលលើដែនកំណត់នៃការប្រើប្រាស់ថ្នាំបន្សាបមុននឹងប្រើប្រាស់។ |
| – បន្តដោយដាក់ក្នុងសេរ៉ូម 0.4 - 4mg ក្នុង ១ ម៉ោង ដើម្បីរក្សាសញ្ញាខាងលើ។ | គោលដៅ គឺបន្ត Atropin រហូតដល់៖<br>• ស្តាប់សួតទៅមិនលឺសម្លេងស្លេស (គ្រលៗ)<br>• ជីពចរ លើសពី 80/min<br>• សម្ពាធស៊ីស្តូល លើស 80 mmHg |

**សម្គាល់**

⇨ ត្រូវបញ្ឈប់ប្រសិនបើមានសញ្ញាពុល Atropine ដូចជា៖
- ឡើងក្តៅខ្លួន
- ចេញសញ្ញា វង្វេង
- ស្តាប់មិនមានសូរពោះវៀនដើរ ( Peristalsis) ឬ នោមមិនចេញ

⇨ Atropine មានប្រសិទ្ធភាពតែលើអាការៈ ចុកពោះ រាគ បែកញើសច្រើន លេចនោម ហៀរទឹកភ្នែក ហៀរសំបោរ ឡើងស្លេះ បេះដូងដើរយឺត តឿតទងសួត កូនក្រមុំភ្នែករួមតូចប៉ុណ្ណោះ។ មិនអាចប្រើការពារទុកជាមុនទេ។

៩.១.២ ថ្នាំបន្សាប (Antidote)៖ OXIMES

| ការព្យាបាលដំបូង | កំណត់ចំណាំ និងការព្យាបាលគាំទ្រ |
|---|---|
| ⇨ មនុស្សពេញវ័យ៖ Pralidoxime (ជា chloride ឬ mesylate salt): 30mg/kg (រហូតដល់ 2g) ចាក់ IV យឺតៗ។ ចាក់ឡើងវិញរៀងរាល់ ៤-៦ ម៉ោងម្តង ឬផ្តល់ infusion 8-10 mg/kg/hr។<br>**សម្គាល់៖**<br>⇨ 30mg/kg IV សម្រាប់មនុស្សពេញវ័យ (ក្មេងតូច 30mg/kg មិនលើសពី 1g) លាយក្នុងសេរ៉ូមប្រៃ ដាក់ក្នុងរយៈពេល ៥-១០ នាទី។<br>⇨ បន្តមកដាក់ក្នុងសេរ៉ូមបន្ត 8mg/kg/h រយៈពេល ២៤-៤៨ម៉ោងទៀត។<br>⇨ អាចប្រើវិធីមួយទៀត៖<br>○ ចាក់សរសៃ 1-2g ដំបូង។ អ្នកជម្ងឺនៅមានទន់ដៃជើង បន្ថែម ១ដូសទៀត នៅពេល ១ ម៉ោងក្រោយ។ រួចបន្តមក ចាក់រៀងរាល់១២ ម៉ោងម្តង ពី៣-៤ដង ។<br>○ បើគ្មានសរសៃចាក់ អាចប្រើចាក់សាច់ដុំក៏បាន ៖ ចាក់សាច់ដុំ ដូស 600mg IM ចាក់បន្ថែម រៀងរាល់ ១៥នាទីម្តង ចាក់ ៣ដង ក្នុង ១ ម៉ោង រហូតដល់អាចកម្រើកដៃជើងបានវិញ។<br>○ ជាការប្រសើរបើ ដាក់ Oxime ទន្ទឹមគ្នានឹង Atropine សេរ៉ូម។<br>ឬ Obidoxime: 250 mg ចាក់ IM ឬ IV យឺតៗ បន្ទាប់មក infusion 750 mg ក្នុងរយៈពេល ២៤ ម៉ោង។ កម្រិតអតិបរមាក្នុងមួយថ្ងៃ 1000 mg។<br><br>**កុមារ៖** Pralidoxime (ជា chloride ឬ mesylate salt): 15-30 mg/kg ចាក់ IV យឺតៗ។ ចាក់ឡើងវិញនៅ 30-60 នាទី បន្ទាប់មកនៅចន្លោះពេលមួយម៉ោងសម្រាប់ 1-2 ដូស តាមការចាំបាច់។<br>ឬ Obidoxime: 4-8 mg/kg ដោយ IV យឺតៗ; ក្នុងករណីចាំបាច់ បន្ទាប់មក infusion ជាមួយ 10 mg/kg/24 ម៉ោង។ | • ដើម្បីជំរុញ Reactivate acetylcholinesterase ឡើងវិញ។<br>• Oximes ផ្សេងទៀតដូចជា HI-6 អាចត្រូវបានប្រើប្រាស់ ប៉ុន្តែមិនទូលំទូលាយទេ។<br>• ទម្រង់ autoinjector គឺមានសម្រាប់ថ្នាំបន្សាបប្រភេទទាំងនេះ។ ស្តង់ដា autoinjector គឺសម្រាប់មនុស្សពេញវ័យប៉ុណ្ណោះ៖ ម្ជុលវែងពេកសម្រាប់សាច់ដុំរបស់កុមារតូចៗ ហើយកម្រិតថ្នាំបន្សាបក៏ខ្ពស់ពេកដែរ។ ការប្រើប្រាស់ autoinjector ស្តង់ដា អាចត្រូវបានពិចារណាក្នុងករណីកុមារពុលធ្ងន់ធ្ងរដែលត្រូវការការព្យាបាលបន្ទាន់ ទោះជាយ៉ាងណាក៏ដោយ ដែនកំណត់ដែលបានរៀបរាប់គួរតែត្រូវបានយកមកពិចារណា។<br>• ការព្យាបាលទ្រទ្រង់ផ្សេងៗទៀត តាមការចាំបាច់៖<br>○ អ្នកជំងឺខ្សោយផ្លូវដង្ហើម ត្រូវការជំនួយម៉ាស៊ីនដង្ហើម<br>○ អ្នកជំងឺប្រកាច់ ត្រូវការ Benzodiazepines IV<br>○ ហាត់ត្រូវការថែម អុកស៊ីសែន។ |

**សម្គាល់**

- ❖ Pralidoxime: ex. Protopam® 1g ក្នុង ១ដប សម្រាប់ចាក់
- ❖ Atropine: សម្រាប់ចាក់ អាចមាន ដូចជា 0.05 mg/mL, 0.1 mg/mL, 0.4 mg/mL, 1 mg/mL

## ឯកសារយោង

**Interim Guidance Document**

Initial Clinical Management of Patients Exposed to Chemical Weapons

World Health Organization